# កម្រង
# រឿងជោគជ័យ

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច
និងការអភិវឌ្ឍសេដ្ឋកិច្ច ជំហាន២

**LASED II**



គជអប
NCDD

ឆ្នាំ ២០១៩

# “បានមករស់នៅលើដីថ្មីនេះ ដូចខ្ញុំបានកើតម្ដងទៀតអីចឹង!”

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ គឺជាសមាសធាតុសំខាន់មួយរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចជំហាន២ (LASED II) ចាប់ពីឆ្នាំ ២០១៦ ដល់ឆ្នាំ២០២១ នៅក្នុងទីតាំងដីសម្បទានសង្គមកិច្ចទាំង១៤ កន្លែង នៅក្នុងខេត្តគោលដៅទាំង ៥ រួមមាន ខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ ត្បូងឃ្មុំ និងក្រចេះ ដែលអនុវត្តគម្រោង LASED II។ ជាក់ស្ដែង សម្បទានិកចំនួន ៧៧៦ គ្រួសារ ដែលទទួលបានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលវត្ថុ កាលពីខែមីនា ឆ្នាំ២០១៨ បាននិងកំពុងរស់នៅអាស្រ័យផលលើដីសម្បទានសង្គមកិច្ច ដែលពួកគាត់បានទទួល ស្ថិតក្នុងឃុំទីពោ ស្រុកសន្ទុក ខេត្តកំពង់ធំ កំពុងទទួលបានប្រយោជន៍យ៉ាងច្រើនពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់គម្រោង។

*“អត់ផ្លូវ ដូចយកពលរដ្ឋទៅទុកចោលក្នុងព្រៃអីចឹង”* នេះជាការលើកឡើងរបស់លោក ប៉ែន តូ ដែលជាសមាជិកក្រុមប្រឹក្សាឃុំទីពោ ស្រុកសន្ទុក ខេត្តកំពង់ធំ ដែលកាលពីមុនលោកជាប្រជាពលរដ្ឋក្រីក្រ និងគ្មានដីនៅឃុំពីពោ។ បន្ទាប់មកលោកត្រូវបានជ្រើសរើសជាសម្បទានិកនៅឃុំទីពោតំបន់ ១ និងធ្លាប់ជួយសម្របសម្រួលការងារគម្រោង LASED នៅដំណាក់កាលសាកល្បងដែលមានតួនាទីជាជំនួយការស្មៀនឃុំ។



លោក ប៉ែន តូ បាន រៀបរាប់ទាំងទឹកមុខស្ងួតថា *“កាលពីមិនទាន់មានគម្រោង LASED ផ្លូវចូលទៅកាន់ទីតាំងដីនោះតូច ចូលតែរទេះគោមួយស្មើរតែមិនរួច ហើយការធ្វើដំណើរក៏ចំណាយពេលយូរដែរ ពេលខ្លះត្រូវដេកពាក់កណ្ដាលផ្លូវក៏មាន តែពេលនេះ ទៅមកទីនោះ យើងមិនបាច់*

*ដេកផ្លូវទេ*”។ លោកកំពុងនិយាយពីផ្លូវមេគ្រួសក្រហមមួយខ្សែប្រវែងជាង ១១ គីឡូម៉ែត្រ ដែលស្ថាប នាដោយគម្រោង LASED II ដែលតភ្ជាប់ពីផ្លូវគ្រួ សក្រហមរបស់ឃុំទីពោចូលទៅទីតាំងដីសម្បទានសង្គមកិ ច្ច។ លោកបានបន្ថែមថា ផ្លូវនេះមិនត្រឹមតែបម្រើឱ្យការធ្វើដំណើររបស់ប្រជាពលរដ្ឋទៅកាន់ទីតាំងដីសម្បទានសង្គម កិច្ចប៉ុណ្ណោះទេ ថែមទាំងជាផ្លូវដែលតភ្ជាប់ទៅឃុំផ្សេងៗទៀត ហើយវាក៏បម្រើជាប្រយោជន៍ដល់ប្រជាពលរដ្ឋទូទៅផងដែរ។ លោកបន្ថែមថា *“ផ្លូវមេគ្រួសក្រហមនេះ ជាផ្លូវសម្រាប់ដឹកកសិផល ដឹកបញ្ជូនអ្នកជំងឺ ឬស្ត្រីមានផ្ទៃពោះទៅមណ្ឌលសុខភាព និងងាយស្រួលក្នុងការធ្វើទំនាក់ទំនងគ្នាទៅវិញទៅមក*”។



***“បានមករស់នៅលើដីថ្មីនេះ***
***ដូចខ្ញុំបានកើតម្តងទៀតអីចឹង!”***

នេះជាការលើកឡើងរបស់លោកស្រី ឈឹម សុខឡូន ដែលជាសម្បទានិករស់នៅក្នុងភូមិសែនអភិវឌ្ឍន៍១ ឃុំទីពោ ស្រុកសន្ទុក ខេត្តកំពង់ធំ។ លោកស្រីបានទទួលស្គាល់ថា ការអភិវឌ្ឍផ្លូវមេគ្រួសក្រហមមួយខ្សែនេះ ពិតជាបានផ្តល់ផលប្រយោជន៍យ៉ាងច្រើនដល់សម្បទានិកទាំងអស់។

លោកស្រីបានលើកឡើងថា *“បើអត់មានផ្លូវវាលំបាក ពេលឈឺថ្កាត់យប់ព្រលប់អីអ៊ុំចឹង ពិបាកណាស់ ពិបាកធ្វើដំណើរ។ ពេលឥឡូវបានផ្លូវស្រួល គ្រាន់យើងឈឺថ្កាត់អីទៅ [មណ្ឌលសុខភាព] ផ្លូវស្រួល ហើយស្រួលទៅផ្សារទៅអីគ្រាន់ស្រួលទិញសម្ភារៈប្រើប្រាស់*”។


WSSCC



ក្នុងវ័យ៤១ឆ្នាំ លោក ជឹក ជន ធ្លាប់ជាប្រជាពលរដ្ឋសាមញ្ញ កាលរស់នៅភូមិចាស់នៅឯភូមិស្រែស្រម៉ ក្នុងឃុំទីពោ។ បន្ទាប់ពីលោកបានផ្លាស់ប្តូរទីលំនៅមករស់នៅលើដីសម្បទានសង្គមកិច្ចដែលរាជរដ្ឋាភិបាលបានចែកជូន លោកត្រូវបានជ្រើសរើសជាមេភូមិសែនអភិវឌ្ឍន៍១ ឃុំទីពោ ស្រុកសន្ទុក។ លោកបានទទួលស្គាល់ថា *"កាលពីមុនផ្លូវលំបាក តែទៅហើយមិនចង់មកវិញទេ តែបើមកដល់ហើយ មិនចង់ទៅវិញដែរ។ តែឥឡូវផ្លូវស្រួលហើយ។ បានផ្លូវស្រួល យើងស្រួលទៅមកបានលឿន"*។

ទាំងលោកស្រី ឈឹម សុខឡុន ទាំងលោក ជឹក ជន បានលើកឡើងដូចគ្នាថា ជីវភាពរបស់ពួកគាត់កាន់តែប្រសើរឡើង តាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនានា ជាពិសេសផ្លូវមេគ្រួសក្រហមនេះ។ អ្នកទាំងពីរលើកឡើងថា កាលពីមុន ទោះបីជាពួកគាត់ដាំដុះកសិផលបាន ឬចិញ្ចឹមសត្វបានសម្រាប់លក់ដូរ ក៏គ្មានឈ្មួញចូលទៅទិញដែរ ព្រោះផ្លូវលំបាកពេក ប៉ុន្តែបន្ទាប់ពីគម្រោងបានស្ថាបនាផ្លូវមេគ្រួសក្រហមនេះរួចមក ឈ្មួញបានចូលទៅទិញកសិផល និងសត្វចិញ្ចឹមផ្សេងៗរបស់សម្បទានិកដល់ផ្ទះតែម្តង ដែលធ្វើឱ្យសម្បទានិកងាយស្រួលលក់ដូរ និងបង្កើនជីវភាពរបស់ខ្លួន។

តាមរយៈផ្លូវមេគ្រួសក្រហមមួយខ្សែនេះ លោក ប៉ែន តូ មានប្រសាសន៍បន្ថែមថា *"ខ្ញុំគិតថា ៧០% នៃចំណូលរបស់ប្រជាពលរដ្ឋបានមកពីការប្រើប្រាស់ផ្លូវមេគ្រួសក្រហមនេះ"*។

នៅពេលគេធ្វើដំណើរតាមផ្លូវមេគ្រួសក្រហមឆ្ពោះទៅកាន់ទីតាំងដីសម្បទានសង្គមកិច្ចក្នុងឃុំទីពោ គេនឹងឃើញសំណង់អគារ ហេដ្ឋារចនាសម្ព័ន្ធជាច្រើនទៀតដែលក្នុងនោះមានអគារសាលាបឋមសិក្សាផងដែរ។ តាមផែនការ គម្រោង LASED II បានសាងសង់អគារសាលាបឋមសិក្សាថ្មីចំនួន ១ខ្នងបន្ថែមទៀត ដើម្បីឱ្យកូនៗរបស់សម្បទានិកមានឱកាសបានចូលរៀនគ្រប់ៗគ្នា។ *"ការបង្កើតសាលាបឋមសិក្សានៅក្នុងទីតាំងដីសម្បទានសង្គមកិច្ចនេះ មិនត្រឹមតែអាចឱ្យកូនៗរបស់សម្បទានិកចូលរៀនបានទេ កូនៗរបស់អ្នកភូមិដែលនៅជាប់នឹងដីសម្បទាននេះក៏អាចមកចូលរៀនបានដែរ"* នេះជាការលើកឡើងរបស់លោក ប៉ែន តូ។ តាមការសង្កេតកន្លងលោកមើលឃើញថា *"ឪពុកម្តាយភាគច្រើនបានឱ្យកូនៗរបស់ពួកគាត់ទៅសាលារៀន ព្រោះពួកគាត់គិតថា កាលណាកូនៗមានចំណេះដឹង ពួកគេនឹងចេះគិតវែងឆ្ងាយ មិនឆាប់ចាញ់តាមការបោកបញ្ឆោតរបស់អ្នកដទៃ អាចមានការងារធ្វើត្រឹមត្រូវ ចេះអភិវឌ្ឍខ្លួន និងចេះសម្រេចចិត្តបានត្រឹមត្រូវ"*។



លោក ជឹក ជន បានគាំទ្រទៅនឹងការលើកឡើងរបស់លោក ប៉ែន តូ ថា “*បើគ្មានហេដ្ឋារចនាសម្ព័ន្ធទេ យើងមិនអាចរស់នៅបានទេ ដូចជាសាលារៀន បើគ្មានសាលារៀន កូនយើងមិន បានចូលរៀន ហើយបើយើងឱ្យកូនទៅរៀនឆ្ងាយ យើងបារម្ភពីគេ*”។

នៅពេលគេធ្វើដំណើរចូលទៅដល់ទីតាំងដីសម្បទានសង្គមកិច្ច គេឃើញមានផ្លូវដីស ឬផ្លូវគ្រួសក្រហមខ្វាត់ខ្វែងកាត់ទទឹងផ្លូវមេគ្រួសក្រហមចូលទៅកាន់លំនៅឋានរបស់សម្បទានិកដែលមើលទៅ ហាក់ដូចជាបុរីនៅជនបទដូច្នោះដែរ។ នៅទីនោះ ពួកគាត់បានទទួលដីលំនៅឋានទំហំ ៣០ គុណ៤០ ម៉ែត្រ និងបានសង់ផ្ទះទៅតាមលទ្ធភាពរបស់គ្រួសារនីមួយៗ។ ចំពោះដីដែលនៅសេសសល់ជុំវិញផ្ទះ ពួកគាត់បានដាំដើមផ្លែឈើហូបផ្លែ ដាំបន្លែផ្សេងៗ ហើយគ្រួសារ មួយ ចំនួនបានធ្វើទ្រុងចិញ្ចឹមមាន់ ទា និងសត្វគោ ក្របី ថែមទៀតផង។ ដើម្បីជួយសម្រួលដល់ការដាំបន្លែ និងចិញ្ចឹមសត្វរបស់ពួកគាត់ គម្រោង LASED II ក៏បានសាងសង់អណ្តូងទឹកស្នប់ នៅតាមលំនៅឋាន និងបានសាងសង់ប្រព័ន្ធធារាសាស្ត្រខ្នាតតូច និងអាងស្តុកទឹកនៅទីតាំងសំខា ន់ ៗមួយចំនួនដើម្បីឱ្យពួកគាត់ប្រើប្រាស់ជាលក្ខណៈគ្រួសារ និងប្រើប្រាស់រួមផងដែរ។

លោក ប៉ែន តូ បានបន្តទៀតថា កា លពីមិនទាន់មានគម្រោង LASED II ប្រជាពលរដ្ឋដែ ល ចូលទៅទីនោះប្រើប្រាស់តែទឹកអូរ ហើយអូរនោះនៅឆ្ងាយពីក ន្លែងដែលពួកគាត់រស់នៅ ដែលត្រូវចំណាយពេលច្រើនទៅដងទឹកពីអូរយកមកប្រើប្រាស់។ “*ពេលនេះគម្រោងបានជីកអណ្តូងស្នប់ ហើយប្រជាពលរដ្ឋក៏បាន ជីកអណ្តូងដាក់លូប្រើស្ទើរគ្រប់ផ្ទះ។ វាងាយស្រួលជាងមុន មិនចំណាយពេលទៅដងទឹកនៅតាមអូរទឹកស្អាត អាចប្រើប្រាស់បាន និងមានពេលវេលាទៅដាំដុះ និងធ្វើការងារផ្សេងៗ*” នេះជាការលើកឡើងរបស់លោក ប៉ែន តូ សមាជិក ក្រុម ប្រឹក្សា ឃុំទីពោ។

ក្រៅពីហេដ្ឋារចនាសម្ព័ន្ធដែលបានរៀបរាប់ខាងលើ គម្រោង LASED II ក៏បានសាងសង់អគារសហគមន៍សម្រាប់ប្រើប្រាស់នៅពេលប្រជុំ ឬរៀបចំពិធីផ្សេងៗ វត្តអារាមសម្រាប់សម្បទានិករៀបចំកម្មវិធីបុណ្យទាន ប៉ុស្តិ៍សុខភាព អគារស្នាក់នៅរបស់គ្រូបង្រៀន និងគិលានុបដ្ឋាកយិកា ដើម្បីឱ្យសម្បទានិកអាចពិនិត្យ និងទទួលថ្នាំព្យាបាលមួយចំនួន និងដើម្បីលើកទឹកចិត្តដល់គ្រូបង្រៀន និងគិលានុបដ្ឋាកឱ្យមកបំពេញការងារនៅក្នុងទីតាំងដីសម្បទានសង្គមកិច្ចេះឱ្យកាន់តែមានប្រសិទ្ធភាពផងដែរ។

តាមរយៈការផ្តល់ដីសម្បទានសង្គមកិច្ចជាដីលំនៅឋាន

និងដីកសិកម្មជាលក្ខណៈគ្រួសារ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តគ្រប់បែបយ៉ាងនេះ សម្បទានិកដែលបានមករស់នៅទីនេះសុទ្ធតែបានសម្តែងក្តីរីករាយ និងបានបង្ហាញពីភាពរីកចម្រើនផ្នែកជីវភាពរស់នៅរបស់ពួកគាត់ផងដែរ។

លោកស្រី ឈឹម សុខឡូន និយាយទាំងទឹកមុខញញឹមថា កាលពីមុន *“ខ្ញុំគ្មានដីសម្រាប់សង់ផ្ទះទេ ហើយក៏គ្មានដីដាំដុះដំណាំផ្សេងៗដែរ។ ពេលមកនៅទីនេះ [ដីសម្បទានសង្គមកិច្ច] ខ្ញុំមានដីសង់ផ្ទះ មានដីធ្វើស្រែចម្ការ ហើយអាចរកស៊ីផ្សេងៗ ដើម្បីផ្គត់ផ្គង់ជីវភាពរាល់ថ្ងៃបានទៀតផង។ ចំពោះជីវភាពវិញ មករស់នៅទីនេះ [ដីសម្បទានសង្គមកិច្ច] ខ្ញុំឃើញភាគច្រើនប្រជាពលរដ្ឋធូរធារច្រើនជាងរស់នៅទីនោះ [ភូមិចាស់] ឆ្ងាយណាស់”*។ នេះជាការលើកឡើងរបស់លោក ជឹក ជន។ គាត់បានបន្ថែមថា *“ពេលប្រជាពលរដ្ឋបានមករស់នៅទីនេះ គាត់ខំប្រឹងជាងមុនឆ្ងាយ ហើយគាត់រកបានចំណូលច្រើនជាងមុន។ កាលពីមុនគាត់ស៊ីឈ្នួលគេ តែពេលនេះគាត់លែងចង់ហើយ គឺគាត់ប្រឹង ធ្វើ[ដាំដុះ] ដោយខ្លួនឯង”*។ លោក ប៉ែន តូ សម្តែងអារម្មណ៍ថា *“ខ្ញុំមានអារម្មណ៍រំភើប និងត្រេកអរណាស់ដែលឃើញប្រជាពលរដ្ឋរីកចម្រើន តាំងពីអត់ដីរហូតមានដី តាំងពីអត់មធ្យោបាយធ្វើដំណើរ រហូតមានម៉ូតូ មានគោយន្តសម្រាប់ប្រើប្រាស់ធ្វើឱ្យជីវភាពគ្រួសាររីកចម្រើន”*។

ទូរស័ព្ទលោក ប៉ែន តូ÷ 012 714 450
ទូរស័ព្ទលោកស្រី ឈឹម សុខឡូន÷ 088 49 84 780
ទូរស័ព្ទលោក ជឹក ជន÷ 011 476 205











# ការចាប់ផ្ដើមជីវភាពពីបាតដៃទទេរបស់សម្បទានិកគម្រោង LASED II

ក្នុងវ័យ៤៨ឆ្នាំ លោកស្រី ឌឹម ចន្ទ ជាសម្បទានិករបស់គម្រោងបែងចែកដីដើម្បី សង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចជំហាន២ (LASED II) ស្ថិតនៅក្នុងភូមិអូរគគីរ ឃុំដារ ស្រុកចិត្របុរី ខេត្តក្រចេះ។ ដោយមានកូនចំនួន៦នាក់នៅក្នុងបន្ទុក គ្រួសារលោកស្រីបានចូលមករស់នៅលើដីសម្បទានសង្គមកិច្ចនេះ តាំងពីឆ្នាំ២០១២ ដោយបានចាប់ផ្ដើមសង់ជម្រកស្នាក់នៅលើដីឡូតិ៍លំនៅឋាន និងធ្វើកសិកម្មលើដីឡូតិ៍កសិកម្មរហូតមកដល់សព្វថ្ងៃ។

ដើម្បីជួយសម្រាលការលំបាករបស់សម្បទានិក ដែលស្ទើរតែទាំងអស់ជាប្រជាពលរដ្ឋក្រីក្រ មកពីភូមិនានា នៅក្នុងឃុំដារ គម្រោង LASED II បានផ្តល់បន្ថែមនូវ គ្រឿងបង្គុំផ្ទះ និងសម្ភារៈសម្រាប់ការរស់នៅដូចជាសង្កសី អំពូល និងបន្ទះពន្លឺព្រះអាទិត្យ តង់ប្លាស្ទិក ភួយ កន្ទេល លីឡុង ពាងទឹក ធុងចម្រោះទឹក អង្ក រ និងឧបករណ៍សម្រាប់បម្រើ ដល់ការធ្វើកសិកម្មដូច ជា ផ្លែចបកាប់ ចបជីក កំបិតភ្នាក់ ធុងស្រោចដំណាំ ពូថៅ ប៉ែល រណា ត្រសេះ ព្រមទាំងគ្រាប់ពូជបន្លែរួមមាន គ្រាប់សណ្តែកទ្រើង គ្រាប់ត្រប់វែង គ្រាប់ត្រសក់ គ្រាប់ត្រកួន គ្រាប់ត្រឡាច គ្រាប់ននោង កូនស្វាយចន្ទី កូនដូង កូនទឹកដោះ កូនខ្នុរ និងកូនក្រូចឆ្មារជាដើម។ លើសពីនេះ គម្រោងក៏បានឈូសឆាយដីកសិកម្មចំនួនកន្លះហិកតា ជូនសម្បទានិកក្នុងមួយគ្រ សា រផង ដែរ ដើម្បីបង្កបង្កើនផល។

ទន្ទឹមនឹងការជួយគាំទ្រនានាខាងលើរបស់គម្រោង អ្វីដែលគ្រួសាររបស់លោកស្រី ឌឹម ចន្ទូ នៅត្រូវការជាចាំបាច់ នោះគឺថវិកា។ គ្រានោះ សហគមន៍អភិវឌ្ឍន៍កសិក ម្មត្រូវបានបង្កើតឡើង ដោយសមាសភាគដឹកនាំ និងសមាជិកភាគច្រើនជាសម្បទានិកដែលទើបមកតាំងទីលំនៅថ្មី។

បន្ទាប់ពីបានទទួលព័ត៌មាន ពីការបង្កើតសហគមន៍នោះ គ្រួសារលោកស្រីបានសម្រេចចិត្តខ្ចីលុយពីបងប្អូន ដើម្បីចូលជាសមាជិក និងបានទិញភាគហ៊ុនចំនួន១ហ៊ុន ដែលមានតម្លៃ ១ ម៉ឺនរៀល។





“ ប្រសិនបើមិនបានចូលជាសមាជិកសហគមន៍នេះ ខ្ញុំក៏មិន អាចខ្ចីលុយគេបានដែរ ព្រោះកាលនោះ ខ្ញុំអត់មានអ្វីទាល់តែសោះ” លោកស្រីចន្ធមានប្រសាសន៍ដោយគ្មានភាពអល់អែក។ ការក្លាយជាសមាជិកសហគមន៍កសិកម្មនេះ បានធ្វើឱ្យគ្រួសារលោកស្រីមានឱកាសអាចខ្ចីប្រាក់ពីសហគមន៍ ដើម្បីបង្កបង្កើនផល។ លោកស្រីនិយាយទាំងក្ដីសង្ឃឹមថា “កាលនោះ ខ្ញុំបានខ្ចីលុយពីសហគមន៍ចំនួន ៥៥ ម៉ឺនរៀល យកមកឈូសឆាយដីធ្វើស្រែបានចំនួន ១ ហិកតា បន្ថែមទិញកូនជ្រូកចំនួនពីរក្បាល និងទិញមាន់ចំនួន ៣ ក្បាល សម្រាប់ចិញ្ចឹម”។

ក្នុងរយៈពេលប្រមាណ ៦ ខែក្រោយមក លោកស្រី និងគ្រួសារបានប្រមូលផលស្រូវលក់បានចំនួន ៧៥ ម៉ឺនរៀល និងសល់ស្រូវទុកហូបរហូតដល់ឆ្នាំក្រោយ។ លើសពីនេះ លោកស្រីលក់ជ្រូកពីរក្បាលដែលបានទិញបានប្រាក់ចំនួន ៥៥ ម៉ឺនរៀល និងលក់មាន់បានប្រមាណ ១០ ក្បាលបានប្រាក់ចំនួន ១៨ ម៉ឺនរៀល ហើយលោកស្រី បានសងប្រាក់ដែលបានខ្ចីទៅសហគមន៍វិញ។ រីឯប្រាក់ដែលនៅសល់ លោកស្រីបានយកមកធ្វើជាដើមទុន ដើម្បីបង្កបង្កើនផល ចិញ្ចឹមសត្វ និងដាំបន្លែបន្តទៀត។ ប៉ុន្មានឆ្នាំចុងក្រោយនេះ គ្រួសារលោកស្រីអាចនៅសល់ប្រាក់សន្សំយ៉ាងហោចណាស់ក៏ ៥៥ ម៉ឺនរៀលក្នុងមួយឆ្នាំ ដែលប្រាក់នេះនៅសល់ពីការចំណាយទាំងអស់នៅក្នុងគ្រួសារ។

ដោយមើលឃើញពីសារៈប្រយោជន៍ នៃ កា រចូលជាសមាជិកសហគមន៍អភិវឌ្ឍន៍កសិកម្មនេះ លោកស្រីបានចែករំលែកបទពិសោធន៍នេះទៅសម្បទា និ កដទៃទៀត ដែលមិនទាន់បានចូលជាសមាជិកនៅឡើយ បា នចំនួននាក់បន្ថែមទៀត។ រីឯលោកស្រី ក៏បា ន បង្កើនចំនួនហ៊ុនរបស់ខ្លួនរហូតដល់៥ហ៊ុន ស្មើនឹង៥ម៉ឺនរៀល ដើម្បីទទួលបានប្រាក់ចំណេញកាន់តែច្រើននៅចុងឆ្នាំ។ “បើយើងទុកលុយ យើងនឹងចាយអស់

តែបើយើងចូលរួមដាក់ហ៊ុនវិញ យើងបានទាំងដើមទាំងការមកវិញនៅចុងឆ្នាំ”។

ក្រៅពីការបង្កបង្កើនផលដូចជា ស្ទូងស្រូវ ដាំដំឡូងមី ដាំសណ្ដែកបាយ និងដាំល្ងទៅតាមរដូវកាលនីមួយៗ ដើម្បីផលិតស្បៀង និងលក់ដូរលើដីកសិកម្មរបស់ខ្លួន លោកស្រី ស្វាមី និងកូនៗពីរនាក់របស់គាត់បានឆ្លៀតពេលទៅធ្វើការឱ្យបងប្អូនដែលជាសម្បទានិកក្នុងភូមិបន្ថែមទៀត ដើម្បីបានប្រាក់កម្រៃយកមកដោះស្រាយជីវភាពប្រចាំថ្ងៃ។

ដោយឆ្លងកាត់នូវការតស៊ូឥតស្រាកស្រាន្តក្នុងការចាប់ផ្ដើមជីវិតថ្មីនៅលើដីសម្បទានសង្គមកិច្ចភូមិអូរគគីរ និងដោយមានការជួយជ្រោមជ្រែងគ្រប់សព្វបែបយ៉ាងពីគម្រោង LASED II និងដៃគូអភិវឌ្ឍន៍នានា គ្រួសាររបស់លោកស្រីបានប្រែក្លាយជីវភាពកាន់តែល្អប្រសើរពីមួយថ្ងៃទៅមួយថ្ងៃ។ ក្នុងនោះ គ្រួសារលោកស្រីបានអភិវឌ្ឍជីវភាពគ្រួសារខ្លួនពីផ្ទះខ្ទមតូចមួយ មកជាផ្ទះធ្វើអំពីឈើប្រក់ស៊ីហ្វ្រូស៊ីម៉ង់ទំហំ ៧ x ១០ម៉ែត្រ និងហ៊ុំព័ទ្ធទៅដោយដើមឈើហូបផ្លែស្ទើរគ្រប់មុខ រួមផ្សំនឹងការចិញ្ចឹមគោ ជ្រូក មាន់ និងចំការបន្លែតូចមួយជាលក្ខណៈគ្រួសារនៅក្នុងបរិវេណដីលំនៅឋាននោះ ដែលមើលទៅដីលំនៅឋានទំហំ ២០ x ៥០ ម៉ែត្រស្ទើរតែរកកន្លែងទំនេរគ្មាន។

រំលឹកដល់អតីតកាល និយាយរៀបរាប់ទាំងទឹកមុខស្ងួត និងទឹកភ្នែករលីងរលោងផង លោកស្រី ខឹម ចន្ទ មានប្រសាសន៍ថា “កាលពីមុន [មិនទាន់បានដីសម្បទានសង្គមកិច្ច] ខ្ញុំសុំដីគេសង់ខ្ទមតូចមួយ ហើយដើរស៊ីឈ្នួលគេ រកបានមួយថ្ងៃ ហូបមួយថ្ងៃ។ ខ្ញុំបានចូលមករស់នៅលើដីសម្បទានសង្គមកិច្ចនេះតាំងពីឆ្នាំ២០១២... កាលនោះ ជើងសរសរផ្ទះខ្ញុំប៉ុនៗកដៃ... កាលនោះ សូម្បីលុយមួយរយក៏ខ្ញុំគ្មានដែរ”។





មិនខុសពីលោកស្រី ឌឹម ចន្ទ ទោះបីជាមិនទាន់មានផ្ទះធំសម្រាប់រស់នៅ ប៉ុន្តែលោក យស់ សារ៉េន ដែលជាសម្បទានិករស់នៅក្នុងភូមិអូរគគីរម្នាក់ទៀត កំពុងរស់នៅក្នុងផ្ទះប្រក់សង្កសីតូចល្មម និងហ៊ុំព័ទ្ធទៅដោយបន្លែ និងដើមឈើហូបផ្លែស្មើរគ្រប់មុខ ដោយរីករាយបែបមនុស្សក្នុងវ័យ ចំណាស់ ៦២ ឆ្នាំ។ លោកយស់ សារ៉េន និយាយបណ្តើរ សើច និងញញឹមបណ្តើរ ហាក់ដូចជាគាត់ដឹងថាអ្វីៗដែលគាត់កំពុងមាន គឺជាក្តីប្រាថ្នារបស់មនុស្សភាគច្រើននា ពេ ល បច្ចុប្បន្នដែលប្រាថ្នាចង់បានដីធ្វើចំការតិចតួច និ ង មា នផ្ទះតូចមួយសម្រាប់រស់នៅ ឬសម្រាក លំហែរនៅពេលចាស់។ សព្វថ្ងៃនេះ លោក និងភរិយាមិនព្រួយបារម្ភពីកា រ រ ស់នៅ និងជីវភាពប្រចាំថ្ងៃឡើយ ព្រោះគាត់ដាំដំណាំ ចិ ញ្ចឹ មត្រី ចិញ្ចឹមមាន់ និងដាំដើមឈើហូបផ្លែស្មើរគ្រប់មុខដែលអាចប្រមូលបានផលស្មើរគ្រប់រដូវកាលដែលគ្រប់គ្រាន់សម្រាប់ជីវិតមនុស្សចាស់ដូចជា គ្រួសារលោក។ “ឥឡូវនេះ ខ្ញុំមាន ចំណូលក្នុងមួយថ្ងៃយ៉ាងតិច៥ពាន់រៀលដែលបានមកពីការលក់ដូរផលដំណាំទាំងនេះ” លោក យស់



សារ៉េន បានមានប្រសាសន៍ទាំងញញឹម។ ចំពោះការដាំបន្លែ និងការចិញ្ចឹមសត្វនេះ គ្រួសារលោកបានទទួលឧបករណ៍សម្ភារៈដែលផ្តល់ដោយគម្រោង LASED II ហើយលោកបានខ្ចីថវិកាចំនួន ១០ ម៉ឺនរៀល បន្ថែមពីសហគមន៍អភិវឌ្ឍន៍កសិកម្ម និងក្រុមសន្សំ ដើម្បីទិញគ្រាប់ពូជបន្ថែម ហើយក្នុងរយៈពេលមិនដល់បីខែផង លោកអាចលក់បន្លែដែលបានដាំនោះ និងសងលុយទៅសហគមន៍អភិវឌ្ឍន៍កសិកម្មវិញ និងនៅសល់លុយជាង ១០ ម៉ឺនរៀល ដើម្បីទិញគ្រាប់ពូជដំណាំដាំបន្ត និងដោះស្រាយជីវភាពប្រចាំថ្ងៃ។



សហគមន៍អភិវឌ្ឍន៍កសិកម្មអូរគគីរត្រូវបានផ្តួចផ្តើមបង្កើតឡើងនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១២ ហើយគិតមកត្រឹមឆ្នាំ២០១៨នេះ សហគមន៍អភិវឌ្ឍន៍កសិកម្មនេះ មានសមាជិក សរុបចំនួន ៧១ នាក់ មានភាគហ៊ុនចំនួន ៤០៩ និងមានទុនសរុបចំនួនជាង ១៧លានរៀល។ ប្រធានសហគមន៍អភិវឌ្ឍន៍កសិកម្មអូរគគីរលោកស្រី វេន សារុន មានប្រសាសន៍ ថា “ការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ខ្ញុំមានជីវភាពធូរធារ។ គាត់មានដីលំនៅឋានសម្រាប់ដាំដំណាំហូបចុកប្រចាំថ្ងៃ ។ ដីកសិកម្មសម្រាប់បង្កបង្កើនផលដំណាំវិលជុំ”។ ទោះបីជាយ៉ាងនេះក្តី លោកស្រីមើលឃើញថា សហគមន៍អភិវឌ្ឍន៍កសិកម្មអូរគគីរមានដើមទុនតិចតួចនៅឡើយ សម្រាប់ឱ្យសម្បទានិកខ្ចីប្រើប្រាស់ក្នុងការបង្កបង្កើនផល។ លោកស្រីបន្ថែមថា ប្រសិនបើគម្រោងមានថវិកាសម្រាប់ឱ្យសហគមន៍ខ្ចី ឬផ្តល់កម្ចីឱ្យសម្បទានិកនោះជាការប្រសើរ ព្រោះសហគមន៍អភិវឌ្ឍន៍កសិកម្មរបស់លោកស្រីអាចបង្កើតមុខរបរបន្ថែមដូចជា ទិញប្រេងសាំងសម្រាប់លក់ ទិញចំណីសត្វលក់ និងទិញលក់ផលិតផលកសិកម្ម និងទិញដំឡូងមីរបស់សម្បទានិក ដើម្បីបង្កើនប្រាក់ចំណូលសម្រាប់សហគមន៍អភិវឌ្ឍន៍កសិកម្ម ក៏ដូចជាចែកផលចំណេញទៅសម្បទានិករបស់ខ្លួន។

លោក ភោគ សុទ្ធារិទ្ធ អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ បានទទួលស្គាល់ពីការរីកចម្រើនរបស់សម្បទានិកដែលបានចូលជាសមាជិកសហគមន៍អភិវឌ្ឍន៍កសិកម្មនេះ ហើយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងបន្តកិច្ចសហការជាមួយអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការបន្តផ្តល់វគ្គបណ្តុះបណ្តាលនិងពង្រឹងទាំងសមត្ថភាពនិងបច្ចេកទេសដល់សហគមន៍នេះ។

ចំពោះក្រុមប្រឹក្សាឃុំដារវិញ បានសម្តែងនូវការសាទរ យ៉ាងខ្លាំងចំពោះសហគមន៍កសិកម្មនេះ។ លោក សេង ហេង ប្រធានក្រុមប្រឹក្សាឃុំដារ ស្រុកចិត្របុរី ខេត្តក្រចេះ បានមានប្រសាសន៍ថា ក្រៅពីការផ្តល់ថវិកាជាកម្ចីទៅដល់សម្បទានិកសហគមន៍អភិវឌ្ឍន៍កសិកម្មនេះ បានដើរតួនាទីសំខាន់មួយទៀត គឺការជួយជំរុញសម្បទានិកឱ្យប្រើប្រាស់ដីដែលគម្រោងបានចែក ដើម្បីឈានទៅទទួលបានបណ្ណកម្មសិទ្ធិស្របតាមលក្ខខណ្ឌរបស់គម្រោង។ លោកមានប្រសាន៍ថា “ សហគមន៍នេះជួយដល់សម្បទានិកក្នុងការពង្រីកដីកសិកម្មរបស់ខ្លួន ព្រោះការផ្តល់បណ្ណកម្មសិទ្ធិផ្អែកលើការប្រើប្រាស់ដីរបស់សម្បទានិកអ៊ីចឹងបើសម្បទានិកបានប្រើប្រាស់ដីបានច្រើន ពួកគាត់ក៏មានសិទ្ធិទទួលបានបណ្ណកម្មសិទ្ធកាន់តែច្រើនដែរ”។

ច្បាប់ស្តីពី សហគមន៍អភិវឌ្ឍន៍កសិកម្មត្រូវបានបង្កើតឡើង តាមព្រះរាជក្រម នស/រកម/០៦១៣/០០៨ ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៣ ក្នុងគោលបំណងលើកកម្ពស់ការចូលរួមដោយស្ម័គ្រចិត្តរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូបដែលមានមុខរបរចម្បងក្នុងក្របខ័ណ្ឌនៃប្រព័ន្ធផលិតកម្មកសិកម្ម កសិឧស្សាហកម្ម កសិពាណិជ្ជកម្ម ឬសេវាកម្មពាក់ព័ន្ធផលិតកម្មកសិកម្មក្នុងការបង្កើត និងការអភិវឌ្ឍសហគមន៍កសិកម្ម សំដៅលើកកម្ពស់សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់សមាជិក ព្រមទាំងរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ព្រះរាជក្រមនេះគ្របដណ្តប់លើសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជានៅក្នុងព្រះរាជាណាចក្រកម្ពុជា។

*ទូរស័ព្ទលោកស្រី ឌឹម សន្ធី÷088 54 54 387*

*ទូរស័ព្ទលោក យស់ សារ៉េន÷090 693 298*

*ទូរស័ព្ទលោកស្រី វេន សារុន÷071 31 18 391*

*ទូរស័ព្ទលោក ភោគ សុទ្ធារិទ្ធ÷ 077 665 400*

*ទូរស័ព្ទលោក សេង ហេង÷ 097 21 19 332*




“ឈប់មានជីវិតតែលតោលទៀតហើយ!”

ជាជីវិតដែលលោកស្រី សុ ថាវង្ស កំពុងរស់នៅលើដីសម្បទានសង្គមកិច្ចនៅក្នុងភូមិព្រៃធំ ឃុំរស្មីសាមគ្គី ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ គិតថាមានលំនឹងដោយសារគ្រួសារគាត់មានដីសម្រាប់សង់ផ្ទះសម្បែងសមរម្យ និងអចិន្ត្រៃយ៍ មានដីកសិកម្មសម្រាប់បង្កបង្កើនផល កូនៗបានចូលសាលារៀន ស្វាមី និងលោកស្រីមានការងារធ្វើប្រចាំថ្ងៃ ដើម្បីលើកកម្ពស់ជីវភាពគ្រួសាររបស់ខ្លួន។

ជាជីវិតដែលលោកស្រី សុ ថាវង្ស បានរៀបរាប់ថា កាលពីមុនគាត់បានសុំដីក្រុមហ៊ុនគេ ដើម្បីសង់ខ្ទម និងធ្វើទ្រុងចិញ្ចឹមមាន់។ ដោយសារគេត្រូវការពង្រីកដីដើម្បីអភិវឌ្ឍក្រុមហ៊ុន គេបានប្រាប់ឱ្យគ្រួសារគាត់រើចេញម្តងហើយ ម្តងទៀត។ “គេមកដេញម្តង ខ្ញុំប្រាប់គេថាចាំ២ថ្ងៃទៀត។ ២ថ្ងៃទៀតគេមកម្តងទៀត ខ្ញុំថាចាំស្អែក...មិនដឹងថាត្រូវទៅរស់នៅកន្លែងណា ខ្ញុំចេះតែកុហកគេទៅ”។ លោកស្រីបានរៀបរាប់ទាំងទឹកភ្នែករលីងរលោងហើយបន្តថា នៅពេលនោះគាត់ចេះតែយកកូនៗតាមជាប់ជានិច្ច ហើយពួកគេមិនបានទៅរៀនសូត្រអ្វីឡើយ។ “ខ្ញុំមានកូនច្រើន ខ្ញុំមិនដឹងរកវិធីអីសម្រាប់ចិញ្ចឹមកូនទេ ហើយប្រសិនបើខ្ញុំនៅតែយកកូនទៅតាមចំការអ៊ីចឹង កូនខ្ញុំអត់មានបានរៀន ខ្ញុំដឹងថាអនាគតទៅកូនខ្ញុំមុខជាលំបាកជាងខ្ញុំទៀតហើយ”។

ក្នុងវ័យ៣៨ឆ្នាំ សព្វថ្ងៃលោកស្រី សុ ថាវង្ស និងកូនប្រុសស្រី៥នាក់កំពុងរស់នៅក្នុងផ្ទះប្រក់ស័ង្កសី និងមានជញ្ជាំងធ្វើអំពីឈើនៅលើដីឡូតិ៍លំនៅឋានទំហំ ៣០x៤០ ម៉ែត្រ និងកំពុងបង្កបង្កើនផលលើដីឡូតិ៍កសិកម្ម ទំហំ ១,៥ ហិកតា ដែលទទួលបានពីគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចជំហាន២ (LASED II) ដែលជាកម្មវិធីសម្បទានដីសង្គមកិច្ចរបស់រាជរដ្ឋាភិបាល។ និយាយដោយទំនុកចិត្ត និងស្នាមញញឹម លោកស្រី សុ ថាវង្ស មានប្រសាសន៍ថា *“ខ្ញុំសប្បាយរីករាយមកដល់ទីនេះ គឺដូចជីវិតកើតថ្មីអីចឹង មានដីសម្រាប់បង្កបង្កើនផល មានសាលារៀន មានផ្លូវដើរ មានប៉ុស្តិ៍សុខភាពនៅជិតផ្ទះ... យើងលែងមានជីវិតតែលតោលទៀតហើយ”*។

បច្ចុប្បន្ន កូនស្រីៗពីរនាក់របស់លោកស្រីកំពុងសិក្សានៅអនុវិទ្យាល័យ ហើយកូនស្រីៗពីរនាក់ទៀតកំពុងសិក្សានៅសាលាបឋមសិក្សាព្រៃធំ ដែលគម្រោងបានសាង់សង់។

គិតចាប់តាំងពីការចូលមករស់នៅដំបូង លើដីសម្បទានសង្គមកិច្ចនៅចុងឆ្នាំ២០១២ ក្រៅពីការទទួលបានដីឡូតិ៍លំនៅឋាន និងដីឡូតិ៍កសិកម្ម គ្រួសាររបស់លោកស្រី សុ ថាវង្ស បានទទួលសម្ភារៈសម្រាប់ការសាងសង់លំនៅឋាន សម្ភារៈប្រើប្រាស់នៅពេលចាប់ផ្តើមសង់ជម្រកស្នាក់នៅដំបូង








និងសម្ភារៈសម្រាប់ធ្វើកសិកម្ម។ “ខ្ញុំទទួលបានសង្កសី ធុងទឹក និយាយរួមសម្ភារៈប្រើប្រាស់ក្នុងផ្ទះ ខ្ញុំទទួលបានច្រើន ហើយជាពិសេសពេលមកដល់ទីនេះ កូនខ្ញុំមានសាលារៀន។” លោកស្រីបានរៀបរាប់ ហើយបន្ថែមថា “ពេលយើងមកដល់ដំបូងគឺអាតោកអាតាកណាស់ ប៉ុន្តែខ្ញុំតស៊ូ ខ្ញុំគិតថា ខ្ញុំនៅទីនេះខ្ញុំមានដីសម្រាប់កសិកម្មនិងដីសម្រាប់លំនៅឋានធ្វើឱ្យកូនខ្ញុំរស់នៅ។ អីចឹង ខ្ញុំលំបាកថ្ងៃនេះ តែខ្ញុំសង្ឃឹមថាថ្ងៃក្រោយកូនខ្ញុំអត់លំបាកទេ។

ដើម្បីបង្កើនជីវភាពរបស់ខ្លួន ស្វាមីរបស់លោកស្រី សុថាវង្ស បានទៅធ្វើបុគ្គលិកក្រុមហ៊ុនចំការកៅស៊ូ ចំណែកលោកស្រីនៅផ្ទះមើលថែកូនៗ និងខិតខំដាំដំណាំ ចិញ្ចឹមមាន់ដើម្បីរកលុយបន្ថែមផ្គត់ផ្គង់ការរៀនសូត្ររបស់កូន។ លោកស្រីបានមានប្រសាសន៍ថា “កាលពីមុន ប្តីខ្ញុំធ្វើការនៅក្រុមហ៊ុនបានប្រាក់ខែ ២៥០ដុល្លារអាមេរិក ប៉ុន្តែខ្ញុំអត់មានការងារធ្វើទេ ដេកនៅចាំតែប្រាក់ខែប្តី អីចឹងវាអត់មានអីរីកចំរើនទេ។ ដល់ពេលឥឡូវនេះពេលបានប្រាក់ខែប្តីមក យើងអាចលៃលកមួយផ្នែក ហើយយើងអាចរករបរផ្សេងយើងបានសល់ គ្រាន់ធូរធារជាងមុន”។

ចំពោះដីឡូតិ៍កសិកម្មដែលលោកស្រីទទួលបានពី

គម្រោង លោកស្រី សុ ថាវង្ស បានសង្កត់ធ្ងន់ថា “រាល់ថ្ងៃនេះខ្ញុំធ្វើពេញទំហឹងហ្មង!”។ នៅពេលដល់រដូវបង្កបង្កើនផល ប្ដីរបស់លោកស្រី សុ ថាវង្ស បានសុំច្បាប់គេមកជួយដាំដុះ ហើយគាត់ត្រឡប់ទៅធ្វើការវិញនៅពេលដាំដុះរួច ចំណែកលោកស្រីត្រូវនៅមើលថែបន្ត។ លោកស្រីបានអះអាងថា “ដីកសិកម្មខ្ញុំដាំដំឡូង និងពោត ហើយចំណូលដែលបានមកពីការលក់កសិផលទាំងនេះ ធ្វើឱ្យជីវភាពគ្រួសារខ្ញុំធូរធារខ្លាំងមែនទែន។ ចំពោះការដាំដំឡូងនៅពេលលក់ដូរក្នុងមួយរដូវខ្ញុំនៅសល់លុយជាង១លានរៀលដែរ”។

បន្ថែមលើការដាំដុះ ការចិញ្ចឹមសត្វ និងការធ្វើកសិកម្ម នាពេលបច្ចុប្បន្នលោកស្រី សុ ថាវង្ស ក៏ដូចជាសម្បទានិកជាស្ត្រីដទៃទៀតក្នុងភូមិបានទទួលការបណ្ដុះបណ្ដាលពីមន្ទីរកិច្ចការនារី ក្នុងការកែច្នៃផលិតផលកសិកម្មដែលដាំដុះបានក្នុងសហគមន៍ ដើម្បីលក់ដូរជួយជីវភាពប្រចាំថ្ងៃ។ “ឥឡូវខ្ញុំមានជំនាញមួយទៀតគឺធ្វើចេកឆាប ត្រៀបត្រាវ គឺខ្ញុំអាចរកប្រាក់បានចិញ្ចឹមជីវិតកូន អីចឹងនៅផ្ទះអាចរកលុយបានឱ្យកូនរៀនក្រៅពីរំពឹងលើប្រាក់ខែរបស់ប្ដីខ្ញុំ។ ម្ដងហើយម្ដងទៀត លោកស្រី សុ ថាវង្ស បញ្ជាក់ថា “ខ្ញុំមករស់នៅលើដីសង្គមកិច្ចនេះដូចខ្ញុំកើតសារជាថ្មីអីចឹង។ សូម្បីតែម៉ែឪខ្ញុំក៏អត់មានដីចែកប៉ុណ្ណឹងដែរ។ សម្រាប់ខ្ញុំមានការប្រែប្រួលច្រើនមែនទែន”។ ទូរស័ព្ទលោកស្រី សុ ថាវង្ស÷ ០៩៦ ៤០២ ៦២៨១



ខ្ញុំគ្មានគំនិតគិតថានឹងទៅណាទៀតទេ
គិតថានៅទីនេះតកូន តចៅហើយ!



លោក សៀន វ៉ា គឺជាសម្បទានិកម្នាក់ក្នុងចំណោមសម្បទានិកចំនួន ២៥០ គ្រួសាររបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដែលបានទទួលប័ណ្ណកម្មសិទ្ធិស្របច្បាប់ពីរាជរដ្ឋាភិបាលកាលពីឆ្នាំ ២០១៥។ សព្វថ្ងៃ លោកមានកូនស្រីពីរនាក់ និងកូនប្រុសម្នាក់ ហើយភរិយារបស់គាត់ប្រកបរបរលក់ដូរនៅផ្ទះ ខណៈពេលដែលគាត់បានចំណាយពេលវេលាភាគច្រើននៅចំការ ដើម្បីដាំដុះ និងមើលថែទាំដំណាំដំឡូងមី ស្វាយចន្ទី និងកៅស៊ូនៅលើដីកសិកម្មទំហំ ២ ហិកតារបស់គាត់។

កាលនៅភូមិចាស់ លោក សៀន វ៉ា និងភរិយាមានជីវភាពក្រីក្រ ហើយថែមទាំងជំពាក់លុយគេទៀត ស្របពេលដែលគាត់មានដីតិចតួច ដើម្បីធ្វើចំការ។ បន្ទាប់ពីទទួលបានដីសម្បទានសង្គមកិច្ចពីរាជរដ្ឋាភិបាល គាត់ និងក្រុមគ្រួសារបានចូលមកសង់ជម្រកស្នាក់នៅ និងបានចាប់ផ្ដើមបង្កបង្កើនផលលើដីកសិកម្ម ដើម្បីសងបំណុលគេខ្លះផង និងបង្កបង្កើតជីវភាពថ្មីខ្លះផង។

*“នៅពេលចូលមករស់នៅដំបូង គម្រោងចែកតង់ដែកសម្រាប់សាងសង់ កាំបិត ប៉ោត អង្ករ ឈើ កូនឈើហូបផ្លែ កាលនោះធ្វើផ្ទះទំហំ ៤ គុណ ៦ ម៉ែត្រ”* លោក សៀន វ៉ា និយាយមួយៗ ហើយភ្នែកមើលមិនស្ទូវចំអ្នកសួរសំណួរឡើយ។ ដោយសារដីសម្បទានសង្គមកិច្ចនៅភូមិស្រែលើសែនជ័យ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ មានសក្តានុពលសម្រាប់ដំណាំកសិឧស្សាហកម្ម លោក សៀន វ៉ា បានសម្រេចចិត្តដាំដំឡូងមីលើដីកសិកម្មទំហំពីរហិកតារបស់គាត់។ *“ក្នុងមួយឆ្នាំចំពោះការដាំដំឡូវមីទទួលបានចំណូលចំនួន ៥ ទៅ ៦ លានរៀល បន្ទាប់ពីការចំណាយលើថ្លៃឈ្នួល ឬជីតិចតួច”* លោក សៀន វ៉ា និយាយព្ញៗជាងមុន ហើយចាប់ផ្ដើមញញឹមខ្លះៗ។

នៅពេលចូលរស់នៅដំបូង សម្បទានិកទាំងអស់សុទ្ធតែខ្វះខាត ហើយមន្ត្រី និងអ្នកអនុវត្តគម្រោងក៏ចូលទៅធ្វើការងារនៅទីនោះច្រើនដែរ។ មើលឃើញឱកាសនេះ ភរិយារបស់គាត់ក៏បានប្រមែប្រមូលលុយកាក់តិចតួច ដើម្បីទិញទំនិញផ្សេងៗពីទីផ្សារ យកទៅលក់ដូរនៅផ្ទះក្នុងទីតាំងដីសម្បទានសង្គមកិច្ចដែលនៅឆ្ងាយពីផ្សារ។ *“ចំពោះការលក់ដូរនៅពេលចាប់ផ្ដើមដំបូងទិញតែទំនិញដូចជា គ្រឿងទេសតិចតួច អង្ករត្រឹមមួយបាវព្រោះលក់រាយជាគីឡូ និងភេសជ្ជៈបន្តិចបន្តួច។”* លោក សៀន វ៉ា រៀបរាប់ ហើយគាត់ចេះតែគេចមុខចេញមិនសូវមើលចំអ្នកសួរឡើយ។



ស្របពេលដែលសម្បទានិកក្រីក្រចាប់ផ្ដើមចូលទៅរស់នៅ និងបង្កបង្កើនផលលើដីសម្បទានសង្គមកិច្ច គម្រោងក៏បានចាប់ផ្ដើមស្ថាបនាផ្លូវថ្នល់ សាលារៀន ប៉ុស្ដិ៍សុខភាព អគារសហគមន៍ អណ្ដូងស្នប់ ឈូសឆាយដីកសិកម្ម និងការងារអាទិភាពមួយចំនួនទៀត ដើម្បីផ្ដល់ភាពងាយស្រួលដល់ការរស់នៅប្រចាំថ្ងៃរ បស់សម្បទានិកទាំងអស់។ លោក សៀន វ៉ា បានរៀបរាប់ថា *"ពេលចូលមកនៅដំបូង ឃើញតែព្រៃ ហើយផ្ទះប្រក់ត ង់ ផ្លូវក៏មិនទាន់មាន សាលារៀនក៏គ្មាន ប៉ុស្ដិ៍សុខភាពក៏គ្មាន"*។

ទោះបីជា យ៉ាងនេះក្ដី គ្រួសារលោកមិនដកថយឡើយ។ បន្ទាប់ពីបានទុនខ្លះៗពីការលក់ដំឡូងមីរៀងរាល់ឆ្នាំ ព្រមទាំងការសន្សំប្រាក់មួយចំនួនពីការលក់ដូររបស់ភរិយា ពួកគាត់ឈានដល់ការជួលដីពី ៤ ទៅ ៥ ហិកតារបស់ប្រជាពលរដ្ឋនៅភូមិចាស់មួយចំនួនដែលមិនប្រើប្រាស់ ដើម្បីដាំដំឡូងមីបន្ថែមទៀត។ លោក សៀន វ៉ា ចាប់ផ្ដើមនិយាយដោយមានទំនុកចិត្ត និងរីករាយ *"គិតទាំងដីខ្ញុំ និងដីខ្ញុំជួលគេក្នុងមួយឆ្នាំ ខ្ញុំនៅសល់ប្រាក់ប្រហែលពី ១០ ទៅ ១៥ លានរៀល បន្ទាប់ពីការចំណាយលើថ្លៃកម្មករ ឬការថែទាំផ្សេងៗ"*។

បន្ទាប់ពីការដាំដុះដំឡូងមីអស់រយៈពេលប្រមាណ ៥ ឆ្នាំ



លោក និងភរិយាគិតថា ពួកគាត់គួរប្ដូរមកដាំដំណាំរយៈពេលវែងដែលអាចផ្ដល់ចំណូលជាប្រចាំ និងអាចទាញយកប្រាក់ចំណូលបានយូរអង្វែង។ នៅឆ្នាំ ២០១៤ ពួកគាត់បានចាប់ផ្ដើមប្រែក្លាយដីដែលធ្លាប់ដាំដំឡូងមី ទៅដាំកៅស៊ូ ចំនួន ១ ហិកតា ហើយដីមួយហិកតាទៀត ពួកគាត់ដាំស្វាយចន្ទីនៅឆ្នាំ ២០១៥។ ទោះបីជាយ៉ាងនេះក្ដី គាត់នៅតែបន្តដាំដំឡូងមី នៅតាមចន្លោះរងស្វាយចន្ទី និងរងកៅស៊ូដែលអាចឱ្យពួកគាត់នៅតែអាចប្រមូលផលពីដំឡូងមីរៀងរាល់ឆ្នាំ រហូតដល់ចន្ទី និងកៅស៊ូលូតលាស់ធំ។

សមដូចក្ដីសង្ឃឹម នៅឆ្នាំ២០១៩នេះ ចន្ទីរបស់គាត់ចាប់ផ្ដើមផ្ដល់ផល។ នៅឆ្នាំដំបូងនេះ គាត់លក់ស្វាយចន្ទីបានជាង ២០០ គីឡូក្រាម ដោយទទួលបានថវិកាប្រមាណជាង ១ លានរៀល។ រីឯកៅស៊ូវិញ គាត់ក៏ចាប់ផ្ដើមទទួលបានផលជាលើកទី ១ នៅឆ្នាំ២០១៩នេះដែរ ដោយទទួលបានថវិកាប្រមាណ ២ លានរៀល។ លោក សៀន វ៉ា បានរៀបរាប់ទាំងក្ដីមោទន *“កៅស៊ូយើងអាចជៀរជ័រវាបានជាប់ជាប្រចាំ ហើយរវល់ជាប្រចាំដែរ តែយើងក៏អាចបានចំណូលជាប្រចាំដែរ”*។

ខណៈពេលដែលស្វាមីខិតខំដាំដុះ និងថែទាំដំណាំ ភរិយារបស់លោកក៏មិនបង្អង់ដៃដែរ ដោយគាត់បានខិតខំ



សន្សំលុយមួយកាក់ មួយសេនរបស់គាត់ ដើម្បីពង្រីកការលក់ដូរនៅផ្ទះ និងមើលថែកូនៗផង។

រហូតមកដល់ពេលនេះ គាត់ទិញទំនិញច្រើនប្រភេទ ដូចជាគ្រឿងទេស ភេសជ្ជៈ សាំង បន្លែ ត្រី សាច់ និងរបស់របរជាច្រើនមុខទៀត ជាពិសេសគឺអង្ករ ដែលកាលពីដំបូងគាត់ទិញម្តងតែ ១ បាវ ឥឡូវគាត់ត្រូវទិញម្តង ១ តោន ដើម្បីបម្រើសេចក្តីត្រូវការរបស់សម្បទានិកដែលមានកម្រិតជីវភាពកាន់តែប្រសើរឡើង។ លើសពីនេះ ភរិយាគាត់ក៏បានឆ្លៀតពេលធ្វើម្ហូបអាហារច្រើនមុខ ដើម្បីលក់ជូនសម្បទានិក និងអ្នកដំណើរទៅមកផងដែរ។ *"កាលពីមុនទិញទំនិញម្តងអស់ត្រឹម ១ លានរៀល តែពេលនេះយើងទិញម្តងអស់ ៤ ទៅ ៥ លានរៀល។ បើយើងកាត់ថ្លៃស៊ី ថ្លៃចាយអស់ មួយខែនៅសល់ប្រហែល ៥០ ម៉ឺនរៀល ដែលអាចយកមកប្រើប្រាស់សម្រាប់ជួលកម្មករ ឬប្រើប្រាស់ធ្វើកសិកម្ម"*។ លោក សៀន វ៉ា និយាយទាំងញញឹម និងរីករាយ។ លោកបានបន្ថែមថា របរលក់ដូរនៅផ្ទះ អាចរកចំណូលបានគ្រាន់ចំណាយប្រចាំថ្ងៃលើការហូបចុក សម្លៀកបំពាក់ ថ្នាំសង្កូវ និងការចំណាយលើកម្មវិធីបុណ្យទានផ្សេងៗ និងការសិក្សារបស់កូនៗ ហើយចំណូលដែលបានមកពីការលក់ដំឡូងមី គឺគាត់នៅសល់ទាំងអស់សម្រាប់សន្សំ ឬជួលដីទំនេរបន្ថែមទៀតសម្រាប់ពង្រីកការដាំដំឡូងមីរបស់គាត់។ លោក សៀន វ៉ា លាន់មាត់ថា *"លុយពីធ្វើចំការដឹងតែសល់ហ្នឹង បានប៉ុន្មានក៏ដឹងតែសល់ដែរ"*។

អំឡុងពេលដែលជីវភាពសម្បទាននិកស្ទើគ្រប់គ្រួសារមានការរីកចម្រើន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធលើគ្រប់វិស័យនៅក្នុងទីតាំងដីសម្បទានសង្គមកិច្ចនេះក៏កាន់តែមានរីកចម្រើនផងដែរ។ លោក សៀន វ៉ា បានរស់នៅលើទីតាំងដីសម្បទានសង្គមកិច្ចនេះរហូតមក និងបានកត់សម្គាល់ឃើញនូវការរីកចម្រើនទាំងនេះថា *"បើនិយាយពីខុសគ្នានោះ គឺខុសគ្នាឆ្ងាយណាស់។ ឥឡូវមានសាលារៀន ប៉ុស្តិ៍សុខភាពជួយសម្រួលយើងពេលឈឺយប់ព្រលប់។ កាលពីមុនក្មេងត្រូវទៅរៀនឆ្ងាយ តែ*

*ផ្លូវយើងមានសាលារៀននៅមុខផ្ទះ ស្រួលណាស់ ហើយក្រៅពីនោះមានអគារសហគមន៍ដែលយើងអាចជួបប្រជុំ និងធ្វើកិច្ចការងារផ្សេងៗ។ កាលពីមិនទាន់មានផ្លូវចូលមកដីកសិកម្ម អ្នកទិញចូលមកទិញគេឱ្យថ្លៃតែ ៣ លានរៀលក្នុងមួយហិចតា ចំពោះដំឡូងមី។ ក្រោយពេលមានផ្លូវ គេឱ្យ ថ្លៃ ៣,៥ លានរៀលក្នុងមួយហិតតា។ គម្រោងរៀបចំផ្លូវបែបនេះគឺល្អណាស់ ព្រោះគាត់រៀបចំឱ្យផ្លូវមានគ្រប់មុខផ្ទះប្រជាពលរដ្ឋ។ អនាគតទៅកូនចៅក្រោយៗក៏ងាយស្រួលដែរ ព្រោះមានផ្លូវខ្វាត់ខ្វែង!”*

*សុភាសិតខ្មែរបានពោលថា “ព្យាយាម គង់បានសម្រេច”*។ ក្នុងរយៈពេល ១០ ឆ្នាំ បន្ទាប់ពីគ្រួសាររបស់គាត់បានចូលមករស់នៅលើដីសម្បទានសង្គមកិច្ច នៅភូមិស្រែលើសែនជ័យរួចមក លោក សៀន វ៉ា បានទទួលស្គាល់ថា គ្រួសាររបស់គាត់មានជីវភាពប្រសើរឡើងជាលំដាប់ ដោយសារទាំងគាត់ និងភរិយាបានខិតខំប្រកៀកស្មាគ្នា ដើម្បីកសាងជីវភាពគ្រួសារឡើងវិញ។ នៅដើមឆ្នាំ២០១៩ ទើបគាត់មានថវិកាគ្រប់គ្រាន់សម្រាប់ធ្វើផ្ទះថ្មីទំហំ ៨ គុណ ១៤ ម៉ែត្រ សង់អំពីឈើលើ ថ្មក្រោមក្រាលការ៉ូ និងប្រក់ក្បឿងក្រហមឆ្អិនឆ្អៅ។

លោក សៀន វ៉ា បានរៀបរាប់ថា *“ប្រាក់សម្រាប់សង់ផ្ទះនេះគឺបានមកពីការធ្វើចំការផង និងការលក់ដូរផង”*។ ចាប់តាំងពីការទទួលបានប័ណ្ណកម្មសិទ្ធិនៅឆ្នាំ ២០១៥ លោកបញ្ជាក់ថា លោក និងភរិយាបានខិតខំទ្វេរដង *“តាំងពីទទួលបានប័ណ្ណកម្មសិទ្ធិមក ខ្ញុំនៅតែប្រឹងប្រែងធ្វើ ធ្វើលើសមុនទៀត”*។ លោកបាននិយាយបន្ថែមដោយភាពមោះមុតថា *“ខ្ញុំគ្មានគំនិតគិតថានឹងទៅណាទៀតទេ គិតថានៅទីនេះតកូន តចៅហើយ ព្រោះនៅលើដីសម្បទានហ្នឹង មានសព្វគ្រប់បែបយ៉ាង។ ខាងគម្រោងជួយតាំងពីផ្លូវ សាលារៀន មន្ទីរពេទ្យ ចុះអប់រំកសិកម្មពីការដាំបន្លែ ចិញ្ចឹមសត្វ ចិញ្ចឹមមាន់... ខ្លាចតែយើង គ្មានពេលរៀនទៅទៀត! អ៊ីចឹង ខ្ញុំគិតថាគ្មានទៅភូមិស្រុកណា ល្អជាងរស់នៅលើដីសម្បទានហ្នឹងទេ។ អ៊ីចឹងបានជាខ្ញុំសម្រេចចិត្តថារកលុយកាក់បាន ខ្ញុំធ្វើផ្ទះឱ្យបានធំរស់នៅទីនេះតែម្ដង”*។

*ទូរស័ព្ទ លោក សៀន វ៉ា÷ 097 46 76 553*








# ជីវិតខ្ញុំប្រែប្រួលប្រសើរឡើងច្រើនណាស់



នារដូវប្រាំងក្នុងពេលមានបម្រែបម្រួលអាកាសធាតុ ប្រជាពលរដ្ឋទូទៅជួបផលវិបាកក្នុងការប្រកបរបរកសិកម្ម ជាពិសេសការដាំដុះបន្លែសម្រាប់ការបរិភោគប្រចាំថ្ងៃ និងការលក់ដូរ។ ទោះបីជាយ៉ាងនេះក្តី សម្បទានិកដែលធ្លាប់គ្មានដីប្រើប្រាស់ និងធ្លាប់ធ្វើជាកម្មកររោងចក្រមួយចំនួនរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ជំហាន ២ (LASED II) បានខិតខំជម្នះនូវឧបសគ្គទាំងនោះ ដោយឥតរួញរាឡើយ។

កំពុងធ្វើការនៅក្រោមពន្លឺថ្ងៃ ម៉ោងប្រមាណ ១០ ព្រឹក ខណៈពេលដែលប្រទេសកម្ពុជាកំពុងទទួលរងនូវឥទ្ធិពលបាតុភូតអែលនីញ៉ូ លោកស្រី វ៉ាន់ សុខឃៀង អាយុ ៤៨ ឆ្នាំ ជាសម្បទានិករបស់គម្រោង LASED II រស់នៅភូមិខ្សាច់ស ឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង កំពុងប្រមូលផលបន្លែនៅក្នុងដីកសិកម្មរបស់គាត់។ លោកស្រី សុខឃៀង



ជាសម្បទានិកម្នាក់ក្នុងចំណោមសម្បទានិកចំនួន ២៥៨ គ្រួសារដែលបានទទួលដីលំនៅឋាននិងដីកសិកម្មពីគម្រោង LASED II នៅភូមិខ្សាច់ស។ គាត់ក៏ដូចជាសម្បទានដទៃទៀតដែរបានមានប្រសាសន៍ថា *"ខ្ញុំមានដីតូចមួយនៅភូមិចាស់ ហើយខ្ញុំមិនអាចដាំដុះ ឬធ្វើកសិកម្មបានទេ គឺបានត្រឹមធ្វើខ្ទមតូចមួយប៉ុណ្ណោះ។ ខ្ញុំសប្បាយចិត្តណាស់ដែលបានមករស់នៅទីនេះ [ដីសម្បទានសង្គមកិច្ច] ព្រោះខ្ញុំមានដីគ្រប់គ្រាន់អាចដាំដុះ និងសង់ផ្ទះរស់នៅបាន"*។

លោកស្រី វ៉ាន់ សុខឃៀង ដាំដុះបន្លែជាច្រើនមុខ ដូចជា សណ្តែកទ្រើង ត្រសក់ ប៉េងប៉ោះ ល្ពៅ ត្រកួន និងបន្លែមួយចំនួនទៀតលើដីកសិកម្មទំហំ ១ ហិចតា។ លោកស្រីបានបញ្ជាក់ថា *"បន្ទាប់ពីខ្ញុំទទួលបានដីកសិកម្មនេះ ខ្ញុំមានដីគ្រប់គ្រាន់សម្រាប់ដាំដុះដំណាំ និងមានទឹកគ្រប់គ្រាន់សម្រាប់ស្រោចស្រព។ ខ្ញុំចេះពីរបៀបដាំដុះពីមន្ត្រីកសិកម្មដែលមកបង្រៀនខ្ញុំដល់ភូមិ។ ការដាំដុះបានល្អប្រសើរណាស់"*។ ដោយសារមានការតាំងចិត្តខ្ពស់ និងការព្យាយាមពុះពារនូវឧបសគ្គកាលពីអតីតកាល លោកស្រី វ៉ាន់ សុខឃៀង អាចរកប្រាក់ចំណូល ដើម្បីផ្គត់ផ្គង់ការរស់នៅប្រចាំថ្ងៃ ហើយអាចបញ្ជូនកូនៗពីរនាក់ទៅសាលារៀន។ លោកស្រីនិយាយទាំងញញឹមថា *"ខ្ញុំអាចរកចំណូលបាន២លានរៀលពីការលក់បន្លែទាំងនេះក្នុងមួយរដូវ ដើម្បីព្យាបាលជំងឺម្តាយខ្ញុំ និងផ្គត់ផ្គង់កូនៗពីរនាក់ទៅសាលារៀន"*។ លោកស្រីបានបន្ថែមថា *"បើប្រៀបធៀបការរស់នៅឯភូមិចាស់ ខ្ញុំគិតថារស់នៅទីនេះ [ដីសម្បទានសង្គមកិច្ច] ធ្វើឱ្យជីវិតខ្ញុំប្រែប្រួលប្រសើរឡើងច្រើនណាស់។ ការរស់នៅទីនេះអាចឱ្យខ្ញុំដាំដុះ និងប្រមូលផលបាន ព្រោះមានទឹកគ្រប់គ្រាន់"*។

ក្រៅពីទទួលបានចំណេះដឹងក្នុងការដាំដុះបន្លែ សម្បទានិករបស់គម្រោង LASED II ក៏បានទទួលការបណ្តុះបណ្តាលពីរបៀបចិញ្ចឹមមាន់នៅក្នុងពេលមានបម្រែបម្រួលអាកាសធាតុផងដែរ ដែលជាហេតុធ្វើឱ្យសម្បទានិកនៅតែអាចទទួលបានស៊ុត និងសាច់ ដើម្បីចម្អិនជាម្ហូបអាហារប្រចាំថ្ងៃ និងលក់ដូរខ្លះៗ។ *"ខ្ញុំបានរៀនរបៀបចិញ្ចឹមមាន់ពីអង្គការជីវិតថ្លៃថ្នូ បន្ទាប់មកពី*

អង្គការ GIZ និងក្រោយមកទៀតពីគម្រោង LASED II។ ខ្ញុំអាចរកចំណូលបានជាង ១ លានរៀលពីការលក់មាន់ក្នុងមួយឆ្នាំក្រោយសេសសល់ពីការហូបចុក។ខ្ញុំក៏ចិញ្ចឹមគោខ្លះដែរ ដែលកាលពីឆ្នាំទៅ ខ្ញុំអាចលក់កូនគោមួយក្បាលបានលុយ ១លាន ៤ សែនរៀល។ មួយវិញទៀត ខ្ញុំក៏បានស្ទូងស្រូវ និងដាំសណ្ដែកខ្លីដែលអាចរកចំណូលបានជាង ២ លានរៀលក្នុងមួយឆ្នាំ ហើយឥឡូវនេះខ្ញុំដាំចន្ទីបន្ថែមទៀត។ ជីវិតរបស់ខ្ញុំបានប្រសើរច្រើន ហើយបើប្រៀបធៀបទៅកាលពីមុន”។ លោក ហួត សុខ អាយុ ៣៨ ឆ្នាំ រស់នៅភូមិខ្សាច់ស បាននិយាយទាំងមានទំនុកចិត្ត។ គាត់បានទទួលស្គាល់ថា “រាជរដ្ឋាភិបាលផ្ដល់ដីសម្បទានសង្គមកិច្ចនេះឱ្យខ្ញុំ ស្ថានភាពរស់នៅរបស់ខ្ញុំពិតជាប្រសើរជាងមុន។ មុនពេលខ្ញុំទទួលបានដីសម្បទានសង្គមកិច្ចនេះ ខ្ញុំគ្មានម៉ូតូជិះហ្នឹងគេទេ ហើយក៏គ្មានដីសម្រាប់ដាំដុះដែរ តែពេលនេះខ្ញុំមានដីសម្រាប់ដាំដុះដំណាំ ហើយអាចទិញម៉ូតូមួយគ្រឿងសម្រាប់ធ្វើដំណើរ”។

ទន្ទឹមនឹងការគាំទ្រផ្នែកកសិកម្ម សម្បទានិករបស់គម្រោងកំពុងរីករាយក្នុងការប្រើប្រាស់ និងទទួលផលពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដូចជា ផ្លូវជនបទ សាលារៀន ប៉ុស្តិ៍សុខភាព អគារសហគមន៍ ផ្ទះស្នាក់របស់គ្រូបង្រៀន និងគិលានុប្បដ្ឋាក អណ្ដូងទឹក និងស្រះទឹក។ល។ លោកស្រី វ៉ាន់ សុខឃៀង រាប់ម្រាមដៃ ហើយនិយាយថា “ខ្ញុំឃើញមានសាលារៀន ប៉ុស្តិ៍សុខភាព អគារសហគមន៍ និងផ្លូវល្អៗច្រើនណាស់។ កាលពីមុនវាជាផ្លូវដីស តែឥឡូវនេះប្ដូរមកជាផ្លូវគ្រោះក្រហមហើយ”។ លោកស្រីបានបន្ត ថា “សមិទ្ធផលទាំងនេះបានធ្វើឱ្យជីវភាពយើងប្រសើរឡើង កូនៗយើងអាច ទៅរៀន ហើយមានផ្លូវល្អដើរដែលងាយស្រួលទៅសាលារៀន និងដឹកកសិផលរបស់យើង”។



លោក ហួត សុខ ក៏បានទទួលស្គាល់នូវសមិទ្ធផលនៅលើដីសម្បទានសង្គមកិច្ចនេះដែរ។ លោកបានបញ្ជាក់ថា





*“កាលពីមុនខ្ញុំក្រីក្រណាស់ តែពេលនេះខ្ញុំមានជីវភាពប្រសើរហើយ។ រដ្ឋាភិបាលបានជួយយើង ហេតុនេះបើយើងខំជួយខ្លួនឯងទៀត យើងអាចមាន។ ឥឡូវនេះ ខ្ញុំឃើញមានសាលារៀនប៉ុស្តិ៍សុខភាពនិងផ្លូវដែលអាចដឹកជញ្ជូនកសិផលទៅលក់នៅទីផ្សារ និងងាយស្រួលធ្វើដំណើរទៅធ្វើការងារនៅរោងចក្របន្ថែម។ យើងមានអគារសហគមន៍សម្រាប់ជួបប្រជុំផ្សេងៗ អាចទទួលបានថ្នាំព្យាបាលពីប៉ុស្តិ៍សុខភាព ហើយក្មេងៗអាចទៅសាលារៀនបានគ្រប់ៗគ្នា”។*

គួរបញ្ជាក់ថា គម្រោង LASED II ត្រូវបានអនុវត្តក្នុងភូមិចំនួន ៤ រួមមានភូមិខ្សាច់ស និងភូមិសំបុកក្រៀល នៅឃុំក្រាំងល្វា ភូមិសុខសែនជ័យ នៅឃុំពាម និងភូមិគីរីអភិវឌ្ឍន៍ នៅឃុំឈានឡើង ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។ គម្រោងបាននិងកំពុងរៀបចំស្ថាបនាប្រព័ន្ធធារាសាស្ត្រខ្នាតតូចចំនួនបីទីតាំងក្នុងចំណោមទីតាំងទាំងបួន ដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់ទឹកសម្រាប់បរិភោគ និងការដាំដុះនៅរដូវប្រាំង ស្របពេលដែលប្រទេសកម្ពុជាក៏ដូចជាពិភពលោកទាំងមូលកំពុងទទួលរងនូវឥទ្ធិពលបម្រែបម្រួលអាកាសធាតុសកល។

*ទូរស័ព្ទលោកស្រី វ៉ាន់ សុខឡៀង៖ 097 24 24 931*
*ទូរស័ព្ទលោក ហួត សុខ៖ 068 635 739*









## មានមិនបាន តែមិនដាច់ពោះស្លាប់!

នៅពេលស្វាមី និងកូនៗធ្លាក់ខ្លួនឈឺធ្ងន់ស្ទើរស្លាប់ស្ទើររស់ លោកស្រី អ៊ួច អុក បានបង្ខំចិត្តលក់ដីកេរតូចមួយដែលឪពុកម្តាយបានចែកបន្ទាប់ពីរៀបការរួច ដើម្បីយកប្រាក់ព្យាបាលជំងឺស្វាមី និងកូនៗ។ បន្ទាប់ពីបានលក់ដីនោះរួចមក គាត់ និងគ្រួសារបានសម្រេចចិត្តចាកចេញពីស្រុកកំណើត នៅខេត្តតាកែវ មករស់នៅភូមិក្រាំងដីវ៉ាយ ឃុំរស្មីសាមគ្គី ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ទីដែលគ្រួសារលោកស្រីត្រូវចាប់ផ្តើមពីបាតដៃទទេរនៅកន្លែងថ្មី *“ចេញមកពីនោះ ខ្លួនខ្ញុំស្អាតចេសស្ងួម្បីមួយគ្រាប់ក៏អត់មានដែរ”* នេះជាប្រសាសន៍របស់លោកស្រី អ៊ួច អុក អាយុ ៥១ឆ្នាំ ជាសម្បទានិរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចជំហាន ២ រស់នៅភូមិព្រៃធំ ឃុំរស្មីសាមគ្គី ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។

នៅពេលមកដល់កន្លែងរស់នៅថ្មីនេះ លោកស្រីគ្មានដីសម្រាប់ធ្វើលំនៅឋាន និងធ្វើស្រែចំការដដែល ដោយកាល

នោះលោកស្រីបានខ្ចីដីគេ ដើម្បីធ្វើខ្ទមរស់នៅ និងកាប់រានដីរាល់ថ្ងៃ ដើម្បីធ្វើស្រែយកស្រូវហូប។

*“កាលនោះ មិនមែនមានផ្លូវស្រួលដូចដីសម្បទានពេលនេះទេ គឺខ្ញុំត្រូវហែលឆ្លងកាត់ស្ទឹង ដើម្បីទៅធ្វើស្រែ”* លោកស្រី អ៊ួច អុក និយាយទាំងទឹកភ្នែករលីងរលោង ហើយខ្លួនគាត់ហាក់ញ័របន្តិចនៅពេលរំលឹកដល់គ្រាលំបាក។ *“ក្រៅពីធ្វើស្រែ ខ្ញុំស៊ីឈ្នួលនៅចំការអំពៅហ្គែនឌីស បានលុយ ១២ ០០០ រៀលក្នុងមួយថ្ងៃ សម្រាប់តែទិញអង្ករ និងម្ហូបប្រចាំថ្ងៃ”* លោកស្រី អ៊ួច អុក និយាយដោយមិនលាក់លៀម និងបន្ថែមថា *“បើអត់ធ្វើតែមួយថ្ងៃ គឺអត់បាយដែរ”*។

ដោយមើលឃើញពីភាពក្រីក្រលំបាក និងភាពតស៊ូអត់ធ្មត់របស់គ្រួសារលោកស្រី ស្របពេលដែលរាជរដ្ឋាភិបាលរៀបចំជ្រើសរើសសម្បទានិក ដើម្បីបែងចែកដីសម្បទានសង្គមកិច្ចនៅឃុំរស្មីសាមគ្គី ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ អាជ្ញាធរមូលដ្ឋានបានផ្ដល់ព័ត៌មានដល់គ្រួសាររបស់លោកស្រី ហើយគ្រួសារលោកស្រីក៏បានដាក់ពាក្យស្នើសុំជាសម្បទានិក រហូតជាប់ជាសម្បទានិកអាទិភាព។ *“តាំងពីកើតពោះម៉ែមក អត់មានដីអ៊ីចឹង”* លោកស្រី អ៊ួច អុក បានលាន់មាត់។ ចាប់តាំងពីពេលនោះមក លោកស្រី និងគ្រួសារមានសង្ឃឹមឡើងវិញថានឹងអាចកសាងជីវភាពគ្រួសារឱ្យបានល្អប្រសើរ។

*“បន្ទាប់ពីទទួលបានដីសម្បទានសង្គមកិច្ច ខ្ញុំបានទទួលសម្ភារៈដូចជា កំបិត ពូថៅ រនាស់ ប៉ោតស្រោចទឹកបន្លែ ចបកាប់ គ្រាប់ពូជបន្លែ កូនឈើហូបផ្លែ -ល- ហើយគម្រោងបានភ្ជួររាស់ដីកសិកម្មទំហំ ៧៥ អា”*។ លោកស្រី អ៊ួច អុក បានរៀបរាប់ ដោយយកម្រាមដៃរាប់មួយពីរបណ្ដើផង តែចុងក្រោយគាត់ក្រវីក្បាល ថាចាំមិនអស់ទេ ព្រោះច្រើនពេក។

នៅពេលចូលតាំងទីលំនៅដំបូងនៅឆ្នាំ ២០១២ លោកស្រីបានសាងសង់ផ្ទះធ្វើពីឈើប្រក់ស័ង្កសីទំហំ ៦ គុណ ៨ ម៉ែត្រ ហើយគាត់ចាប់ផ្ដើមស្ទូងស្រូវលើដីកសិកម្មទំហំ ៧៥ អា ដោយទទួលបានផលចំនួនស្រូវចំនួន ៧ បាវ នៅឆ្នាំទី១។ ទិន្នផលនេះមិនគ្រប់គ្រាន់សម្រាប់គ្រួសារគាត់ ដែលមានសមាជិក១០នាក់ឡើយ ហើយពួកគាត់ក៏ខិតខំកាប់គាស់ដីបន្ថែមទៀតរហូតដីកសិកម្មទំហំ ១,៥ ហិចតា វាលស្អាត ហើយគាត់ស្ទូងស្រូវពេញដីនោះ ដោយទទួលបានផលចំនួន ៣០ បាវ នៅឆ្នាំទី២ និងរហូតដល់ ៦០ បាវ នៅឆ្នាំទី៣ និងឆ្នាំបន្តបន្ទាប់។ ដោយ សារការស្រឡាញ់ដី លោកស្រី អ៊ួច អុក មិនធ្លាប់ទុកដីរបស់គាត់ចោលឡើយ ដោយក្នុងមួយថ្ងៃ យ៉ាងហោចណាស់ក៏គាត់ទៅមើលដី និងស្រែស្រូវ ដំណាំរបស់គាត់ម្ដងដែរ *“មានជិតឯណា! ដីកសិកម្មខ្ញុំនៅចម្ងាយជាងពីរគីឡូម៉ែត្រ ទោះបីជាគ្មានអីជិះ ក៏ខ្ញុំដើរទៅដែរ បំណាច់តែខ្ញុំស្រឡាញ់ដី*



*ស្រឡាញ់ដំណាំ*” លោកស្រី អ៊ូច អុក និយាយបណ្ដើ លើកដៃចង្អុលទៅដីកសិកម្មរបស់គាត់ដែលសម្លឹងទៅដាច់កន្ទុយភ្នែក។ ចាប់តាំងពីឆ្នាំ២០១៤មក លោកស្រី និងគ្រួសារហាក់មានជីវភាពកាន់តែប្រសើរឡើង ដោយសារគ្រួសារគាត់មានស្រូវតម្កល់សម្រាប់ហូបពេញមួយឆ្នាំ ហើយអាចសល់ស្រូវសម្រាប់លក់ដូរបានខ្លះទៀត។ លើសពីនេះ គ្រួសារគាត់បានចិញ្ចឹមសត្វរួមផ្សំដូចជា គោ មាន់ ទា ព្រមទាំងដាំបន្លែ ផ្លែឈើជុំវិញផ្ទះ។ ប្រែទឹកមុខខុសពីមុន លោកស្រី អ៊ូច អុក និយាយបណ្ដើរ សើចរលាក់តិចៗបណ្ដើរ “*មិនមានខ្លាំងដូចគេអ្នកជំនួញធំៗទេ តែបើឱ្យដាច់ពោះងាប់គឺមិនងាប់ទេ។ បើយើងអត់មួប មាន់យើងក្នុងទ្រុងមាន បើយើងអត់បាយហូប ស្រូវយើងក្នុងជង្រុកមាន។ អ៊ីចឹងយើងអត់ទិញតែប៊ីចេង ស្ករទេ ដែលយើងមិនបាចផលិតបានដោយខ្លួនឯង។ អ៊ីចឹងមានន័យថា យើងមិនមាន តែមិនដាច់ពោះស្លាប់*”។

ស្បៀអន្តកាលបានរសាត់ទៅឆ្ងាយពីជីវិតរបស់លោកស្រី និងគ្រួសារ។ ចាប់តាំងពីឆ្នាំ២០១៤មក លោកស្រី ស្វាមី និងកូនៗដែលអាចចេញធ្វើការងារបាន បានពួតដៃគ្នាកសាងគ្រួសារនេះពីបាតដៃទទេរ រហូតមានលទ្ធភាពទិញរថយន្តមួយគ្រឿង និងម៉ូតូមួយគ្រឿងសម្រាប់ប្រើប្រាស់។ “*ជីវភាពខ្ញុំបានធូរធារមកដល់សព្វថ្ងៃ គឺបានដីសម្បទាននេះ។ អរគុណ*







*រាជរដ្ឋាភិបាលដែលបានឱ្យដីសម្បទានទោះជាម៉ែឪខ្ញុំក៏គ្មានដីចែកឱ្យដែរ ដីដល់ប៉ុណ្ណឹង!*” លោកស្រី អ៊ួច អុក និយាយយឺតៗ និងសង្កត់ធ្ងន់ៗ។

នៅពេលបច្ចុប្បន្ន តំបន់សម្បទានដីសង្គមកិច្ចនៅភូមិព្រៃធំដែលកាលពីមុនមានតែវាលស្មៅ និងព្រៃរបោះតូចៗ បានក្លាយទៅជាទីក្រុងជនបទមួយដែលមានផ្លូវគ្រោះក្រហមខ្វាត់ខ្វែង សាលារៀន ប៉ុស្តិ៍សុខភាព អគារសហគមន៍ ផ្ទះស្នាក់របស់គ្រូបង្រៀន និងគិលានុប្បដ្ឋាកយិការ អណ្តូងទឹក ស្រះទឹក អមដោយសំឡេងសើចក្អាកក្អាយរបស់សម្បទានិកដែលបង្ហាញពីក្តីសង្ឃឹមសម្រាប់ជីវភាពប្រជាពលរដ្ឋនៅទីនោះ។

បន្ទាប់ពីរស់នៅ និងបង្កបង្កើនផលលើដីសម្បទានសង្គមកិច្ចស្របតាមលក្ខខណ្ឌ និងកិច្ចសន្យា លោកស្រី អ៊ួច អុក ក៏ដូចជាសម្បទានិកនៅភូមិព្រៃធំបានទទួលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ(ប្លង់រឹង) ពីរាជរដ្ឋាភិបាល។ ការនេះបានធ្វើឱ្យលោកស្រីកាន់តែមានទំនុកចិត្តបន្ថែមទៀតក្នុងការកាន់កាប់ និងបង្កបង្កើនផលលើដីដែលរាជរដ្ឋាភិបាលបានចែកជូន។ និយាយដោយភាពស្វាហាប់ និងមួយៗ លោកស្រី អ៊ួច អុក សង្កត់ធ្ងន់ថា “*ទោះបីម៉ែឪយើងក៏អត់បានចែកយើងប៉ុណ្ណឹងដែរ អ៊ីចឹងយើងក៏ត្រូវប្តេជ្ញាថាថែរក្សាដីហ្នឹង ទោះបីយើងរលត់ទៅ នៅសល់ដីហ្នឹងកូនថែរក្សាបន្តទៀត ព្រោះមនុស្សកើតបន្ត ដីអត់កើតទេ! បើទិញចូលបាន បើលក់ដូរកុំអី!*”។ *ទូរស័ព្ទលោកស្រី អ៊ួច អុក÷ 098 827 181*

## អំពីរឿងជោគជ័យ

រឿងជោគជ័យគឺជាឧបករណ៍ផ្សព្វផ្សាយមួយក្នុងចំណោមឧបករណ៍ផ្សព្វផ្សាយជាច្រើនទៀតរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចជំហាន ២ (LASED II) ដែលត្រូវបានរៀបចំឡើងដោយផ្អែកលើព័ត៌មានពិតប្រាកដរបស់សម្បទានិកនៅមុនពេល អំឡុងពេល និងក្រោយពេលដែលសម្បទានិកបានមករស់នៅ និងអាស្រ័យផលលើដីសម្បទានសង្គមកិច្ចរបស់គម្រោង។ គម្រោងបាននិងកំពុងប្រើប្រាស់រឿងជោគជ័យដើម្បីជាការចែករំលែកចំណេះដឹង បទពិសោធន៍ និងវឌ្ឍនភាពរបស់គម្រោងដល់សាធារណៈជនទូទៅ សំដៅលើកកម្ពស់ការយល់ដឹងអំពីគម្រោង និងការចូលរួមបន្ថែមទៀតពីគ្រប់ភាគីពាក់ព័ន្ធក្នុងការបន្តជួយគាំទ្រដល់សម្បទានិក និងគម្រោងទាំងមូល។

លោកអ្នកក៏អាចទាញយកសាច់រឿងជោគជ័យនេះ ដើម្បីអាន និងចែករំលែកបន្តតាមរយៈ÷

http://ncdd.gov.kh/wp-content/uploads/2020/01/LASED-II-Result-story-2018-and-2019.pdf

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច
និងការអភិវឌ្ឍសេដ្ឋកិច្ច ជំហាន២
LASED II